ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ថ្ងៃទី២ ខែតុលា ឆ្នាំ ២០១៤

# សេចក្តីប្រកាសព័ត៌មាន
# លោក ម៉ាទីន ខារ៉ុបគីន ត្រូវបានតែងតាំងជា
# ចៅក្រមអន្តរជាតិបម្រុងថ្មីនៃអង្គជំនុំជម្រះសាលាដំបូង

បន្ទាប់ពីត្រូវបានជ្រើសតាំងដោយឯកឧត្តម បាន គីមូន អគ្គលេខាធិការអង្គការសហប្រជាជាតិ និងទទួលបានការអនុម័តយល់ព្រមពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់បានតែងតាំងលោក ម៉ាទីន ខារ៉ុបគីន (ជនជាតិអាមេរិក) ជាចៅក្រមអន្តរជាតិបម្រុងថ្មី បម្រើការងារនៅអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)។ លោកជំនួសលោកស្រី ក្លឌៀ ហ្វិន (ជនជាតិអូទ្រីស) ដែលត្រូវបានតែងតាំងជាចៅក្រមអន្តរជាតិ នៅអង្គជំនុំជម្រះសាលាដំបូង និងបានចូលកាន់តំណែងនេះតាំងពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ ២០១៤ មក។

ចៅក្រម Karopkin បានទទួលសញ្ញាប័ត្រថ្នាក់បណ្ឌិតផ្នែកច្បាប់ពីសាលាច្បាប់ Brooklyn។ ចាប់ពីឆ្នាំ ២០០៦ ដល់ឆ្នាំ ២០១៤ ចៅក្រម Karopkin គឺជាអនុប្រធានគណៈកម្មការជំនុំជម្រះនៃនាយកដ្ឋាននគរបាលទីក្រុងញូវយ៉កដោយនៅក្នុងតួនាទីនេះ គាត់ជាប្រធានចៅក្រមមួយចំនួនផ្សេងទៀតដែលជាមួយនឹងគាត់ បានគ្រប់គ្រងដំណើរការជំនុំជម្រះលើបញ្ហាវិន័យនៅក្នុងជួរកម្លាំងនគរបាលនៅទីនោះ។ ចៅក្រម Karopkinក៏ធ្លាប់ជាចៅក្រមបម្រុងនៃអង្គជំនុំជម្រះតុលាការកំពូលនៃ អ.វ.ត.ក នៅកម្ពុជា នៅក្នុងដំណាក់កាលបង្កើតវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ក្នុងអំឡុងពីឆ្នាំ ២០០៦ ដល់ឆ្នាំ ២០០៨។ ពីឆ្នាំ ២០០៤ ដល់ឆ្នាំ ២០០៥ គាត់បានបំពេញតួនាទីជាចៅក្រមអន្តរជាតិនៃក្រុមបំពេញបេសកកម្មរដ្ឋបាលបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅ Kosovo។

ចៅក្រម Karopkin ត្រូវបានតែងតាំងដោយចៅហ្វាយក្រុង Edward I. Koch នៅឆ្នាំ ១៩៨៦ ឲ្យបំពេញតួនាទីជាចៅក្រមនៃតុលាការព្រហ្មទណ្ឌក្រុងញូវយ៉ក ហើយគាត់ក៏ត្រូវបានតែងតាំងបន្តម្តងទៀតនៅឆ្នាំ ១៩៩៤ ដោយចៅហ្វាយក្រុង Rudolph Giuliani។ ចៅក្រម Karopkinក៏បានបំពេញតួនាទីជាចៅក្រមស្តីទីនៃតុលាការកំពូល និងជាចៅក្រមស្តីទីនៃតុលាការគ្រួសាររហូតទល់ពេលគាត់ចាកចេញពីតុលាការក្រុងញូវយ៉កនៅឆ្នាំ២០០៣។

ចៅក្រម Karopkin ធ្លាប់បំពេញតួនាទីជាមេធាវីរងនៅស្រុក Brooklyn ក្នុងទីក្រុងញូវយ៉កពីឆ្នាំ ១៩៧២ ដល់ឆ្នាំ ១៩៧៨ និងមានតួនាទីជាឧត្តមសេនីយ៍ត្រួតពិនិត្យនៃនាយកដ្ឋានឧទ្យានទីក្រុងញូវយ៉ក ពីឆ្នាំ ១៩៧៨ ដល់ឆ្នាំ ១៩៨១ និងមានតួនាទីជាឧត្តមសេនីយ៍ត្រួតពិនិត្យនៃនាយកដ្ឋានអគ្គិភ័យទីក្រុងញូវយ៉ក ពីឆ្នាំ ១៩៨១ ដល់ឆ្នាំ ១៩៨៦។

ចៅក្រម Karopkinក៏បានបង្រៀននៅមហាវិទ្យាល័យចិត្តសាស្ត្រនៃសាកលវិទ្យាល័យញូយ៉កក្នុងឋានៈជាសាស្ត្រាចារ្យផ្នែកនីតិចិត្តសាស្ត្រផងដែរ។

For further information, please contact:

Mr. Lars Olsen
Legal Officer
Mobile: +855 (0)12 488 023
Land line: +855 (0)23 861 669
Email: olsenl@un.org

Mr. Neth Pheaktra
Press Officer
Mobile phone: +855 (0)12 488 156
Land line: +855 (0)23 861 564
Email: neth.pheaktra@eccc.gov.kh